# ថេរគ្រឿងសក្ការៈ វិសាខបូជា

អជ្ជាយំ វិសាខបុណ្ណមី សម្បត្តា មយំ ភគវន្តំ សរណំ គតា យោ នោ ភគវា សត្ថា យស្ស ច មយំ ភគវតោ ធម្មំ រោចេម អហោសិ ខោ សោ ភគវា មជ្ឈិមេសុ ជនបទេសុ អរិយកេសុ ឧប្បន្នោ ខត្តិយោ ជាតិយា គោតមោ គោត្តេន សក្យបុត្តោ សក្យកុលា បព្វជិតោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវ មនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ និស្សំសយំ ខោ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ អយំ ខោ បន បដិមាករោ តំ ភគវន្តំ ឧទ្ទិស្សកតោ មយំ ខោ ឯតរហិ ឥមំ វិសាខបុណ្ណមីកាលំ តស្ស ភគវតោ ជាតិ សម្ពោធិ និព្វានកាលស្ស អនុស្សរណត្ថាយ បុប្ផទីបធូបាទិ សក្ការេ គហេត្វា អត្តនោ កាយំ សក្ការុប្បធានំ ករិត្វា តស្ស ភគវតោ យថា ភុច្ចេ គុណេ អនុស្សរន្តា សាធុនោ ភន្តេ ភគវា សុចិរបរិនិព្វុតោបិ ញាតព្វេហិ ករុណាទិ គុណេហិ បញ្ញាយមានោ ឥមេ អម្ហេហិ គហិតេ សក្ការេ អនុកម្បាយ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ព្រះដ៏មានព្រះភាគអង្គឯណា ដែលជាសាស្តាចារ្យ នៃយើងខ្ញុំព្រះអង្គ យើងខ្ញុំព្រះអង្គនឹងញ៉ាំង ព្រះធម៌នៃព្រះដ៏មានព្រះភាគ អង្គឯណាឱ្យរុងរឿង ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បានកើតហើយ ក្នុងមជ្ឈិមជនបទ ជាអរិយប្រទេស ព្រះអង្គមានព្រះជាតិជាខត្តិយៈ មានគោត្តជាព្រះគោតម ទ្រង់ ជាសក្យបុត្តបានយាង ចេញពីសក្យត្រកូលទៅសាងព្រះផ្នួស ហើយទ្រង់បានត្រាស់ដឹងនូវអនុត្តរ សម្មាសម្ពោធិញាណ ប្រសើរផុតក្នុងលោក ព្រមទាំងទេវលោក មារលោក និងព្រហ្មលោក ព្រម ទាំងសមណព្រាហ្មណ៍មនុស្សនិងទេព្តា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្ត ទ្រង់ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះបដិមាដែលតំកល់ទុកនៅទីនេះ ទុកជានិមិត្តរូបស្នងព្រះដ៏មានព្រះភាគអង្គនោះ ។ យើងខ្ញុំព្រះអង្គទាំងឡាយ ក្នុងឱកាសថ្ងៃពេញ បូណ៌មីខែវិសាខនេះ ដើម្បីរំលឹកដល់ ថ្ងៃប្រសូត ថ្ងៃត្រាស់ដឹង និងថ្ងៃបរិនិព្វាន នៃព្រះដ៏មានព្រះ ភាគអង្គនោះ បាននាំយកគ្រឿងសក្ការៈទាំងឡាយ មានផ្កាធូបទៀន ហើយបង្អោនកាយគោរព បូជាចំពោះព្រះគុណដ៏ខ្ពង់ខ្ពស់ នៃព្រះដ៏មានព្រះភាគអង្គនោះ ។

បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ទោះបីព្រះអង្គទ្រង់បានបរិនិព្វានទៅអស់កាលជាយូរអង្វែង ហើយក៏ដោយ តែគុណមានព្រះករុណាទិគុណជាដើមរបស់ព្រះអង្គ នៅតែប្រាកដច្បាស់នៅឡើយ សូមព្រះដ៏មានព្រះភាគអង្គនោះ មេត្តាទទួលនូវគ្រឿងសក្ការៈបូជា ដែលយើងខ្ញុំព្រះអង្គទាំងឡាយ បាននាំមកបូជា ដោយសេចក្តីអនុគ្រោះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំព្រះអង្គទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៊ាន់ អ៊ុទ** អាចារ្យទី១សម្រាប់វត្តធម្មរារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣
វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២

វត្តធម្មារាម

វត្តធម្មារាម

